**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០៤៤៤ សហវ.ទសជ

ថ្ងៃសុក្រ ១២ រោច ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៩

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ:** ករណីសំណើសុំបុរេប្រទានថវិកាជំពូក ៦០ ៦១ និង៦២ ចំនួន ១៣ ៧៩៣ ២៣២ ០០០,០០ រៀល សម្រាប់ចំណាយលើសកម្មភាពជាអាទិភាពចាំបាច់ និងបន្ទាន់ក្នុងឆ្នាំ២០១៩ ។

**យោង:** លិខិតលេខ ៤៧៨៣ អយក.ហវ ចុះថ្ងៃទី១១-០៩-២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យ និងយល់ព្រមធានាចំណាយថវិកា (កម្មវិធីទី ៥ អនុកម្មវិធីទី ៣ ចង្កោមសកម្មភាពទី ១,២ ) ជំពូក **៦០ ៦១ និង៦២** ចំនួន **១៣ ៧៣៧ ៤៧៥ ០០០,០០ រៀល (ដប់បីប៊ីលាន ប្រាំពីររយសាមសិបប្រាំពីរលាន បួនរយចិតសិបប្រាំពាន់រៀលគត់ )** សម្រាប់ចំណាយលើសកម្មភាពជាអាទិភាពចាំបាច់ និងបន្ទាន់ក្នុងឆ្នាំ ២០១៩ ក្នុងនោះ÷

១-ផ្តល់ធានាចំណាយចំនួន ៣ ៧៥២ ៤៧៥ ០០០,០០ រៀល សម្រាប់ចំណាយរៀបចំកិច្ចប្រជុំអន្តរជាតិវេទិកាសកលស្តីពីអាហារូបត្ថម្ភលើកទី ២១ នៅខេត្តសៀមរាប និងជំនួយសង្គមផ្សេងៗទៀត ដោយផ្តល់ជាថវិកាបុរេប្រទានទឹកប្រាក់ចំនួន **២ ២៥១ ៤៨៥ ០០០,០០ រៀល** ស្មើនឹង ៦០% នៃធានាចំណាយសរុប ក្នុងនោះរួមមាន ÷

- អនុគណនី ៦១១០២ ចំនួន ១ ០៣២ ០០០ ០០០៖០០
- អនុគណនី ៦២០២៨ ចំនួន ២ ៧២០ ៤៧៥ ០០០៖០០។

ក្រោយពីការងារត្រូវបានបញ្ចប់ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ចំណាយជាក់ស្តែងមិនឱ្យលើសចំនួន **៣ ៧៥២ ៤៧៥ ០០០,០០ រៀល** ក្នុងនោះអាណត្តិនិយ័តកម្មចំនួន **២ ២៥១ ៤៨៥ ០០០,០០ រៀល (ពីរប៊ីលាន ពីររយហាសិបមួយលាន បួនរយប៉ែតសិបប្រាំពាន់រៀលគត់ )** និងអាណត្តិបើកប្រាក់បង្គ្រប់មិនឱ្យលើសចំនួន **១ ៥០០ ៩៩០ ០០០,០០ រៀល (មួយប៊ីលាន ប្រាំរយលាន ប្រាំបួនរយកៅសិបពាន់រៀលគត់ )** ដោយត្រូវភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ ។

២-ផ្តល់ធានាចំណាយទឹកប្រាក់ចំនួន **៩ ៩៨៥ ០០០ ០០០,០០ រៀល** ដោយក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តវិធីសាស្ត្រចរចា និងចុះកិច្ចសន្យាផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ដែលមានបទពិសោធន៍ល្អជាមួយក្រសួងអប់រំ យុវជន និងកីឡានិងត្រូវអនុវត្តការទូទាត់តាមកិច្ចសន្យា ក្នុងនោះរួមមាន÷

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

| | | | |
|---|---|---|---|
| - អនុគណនី | ៦០០៥៤ | ចំនួន | ៤២០ ០០០ ០០០៖០០ |
| - អនុគណនី | ៦០០៥៥ | ចំនួន | ៤ ៣៣០ ០០០ ០០០៖០០ |
| - អនុគណនី | ៦១០៥២ | ចំនួន | ២ ៧៤០ ០០០ ០០០៖០០ |
| - អនុគណនី | ៦១០៧១ | ចំនួន | ២ ៤៩៥ ០០០ ០០០៖០០ ។ |

ពេលបញ្ចេញអាណត្តិបើកប្រាក់ត្រូវភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាបនិងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**__ចម្លងជូន ÷__**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-ឯកសារ- កាលប្បវត្តិ